CDRI
Cambodia Development Resource Institute

institute of development studies

មិថុនា ២០២៣

# ភាពក្រីក្រ និងសុខុមាលភាពមុន និងអំឡុងពេលមានវិបត្តិកូវីដ-១៩៖ ការវាយតម្លៃចំពោះនិន្នាការ និងកត្តាជាប់ទាក់ទងគ្នា

## ខ្លឹមសារសង្ខេប


ការសិក្សានេះ ពិនិត្យយ៉ាងល្អិតល្អន់នូវកត្តានានាដែលធ្វើឱ្យប៉ះពាល់ដល់សុខុមាលភាព មុនពេលនិងអំឡុងពេលជំងឺកូវីដ-១៩។ ការសិក្សានេះ ប្រើការវិភាគលើទិន្នន័យពីការធ្វើអង្កេតការវាស់វែងកម្រិតជីវភាពកម្ពុជា–រួមបញ្ចូល ឆ្នាំ២០១៩/២០ រួមជាមួយនឹងការធ្វើអង្កេតតាមរយៈការសម្ភាសតាមទូរស័ព្ទអំឡុងកូវីដ-១៩ ចំនួន៥លើក ដែលបានប្រព្រឹត្តទៅនៅចន្លោះខែឧសភា ២០២០ ដល់ខែមីនា ២០២១ ដើម្បីធ្វើការវាយតម្លៃផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចសង្គមដែលបង្កឡើងដោយជំងឺរាតត្បាតនេះ។

លទ្ធផលការសិក្សានេះ ចង្អុលបង្ហាញពីកត្តាមួយចំនួនដែលអាចរួមចំណែកក្នុងការពន្យល់អំពីការកើតឡើងភាពក្រីក្រនៅមុនជំងឺរាតត្បាត។ ទ្រព្យសម្បត្តិ និងធនធានរបស់គ្រួសារនីមួយៗ មានទំនាក់ទំនងសំខាន់ទាក់ទងនឹងសុខុមាលភាព ជាពិសេសទាក់ទងនឹងការមានទូរស័ព្ទដៃប្រើប្រាស់ កម្មសិទ្ធិលើសត្វពាហនៈ និងដីធ្លី និងការមានអគ្គិសនីប្រើប្រាស់។ កត្តាផ្សេងទៀតរួមមាន ការទទួលបានសេវាហិរញ្ញវត្ថុ ការអប់រំ ការប្រកបអាជីវកម្មក្រៅពីវិស័យកសិកម្ម ការធ្វើចំណាកស្រុក និងការផ្ញើប្រាក់មកផ្ទះ។ តួនាទីនៃការផ្ញើប្រាក់មកផ្ទះមានភាពលេចធ្លោជាងគេ ជាពិសេសនៅតាមជនបទ និងសម្រាប់មេគ្រួសារដែលជាស្ត្រី។ បើតាមកត្តាទីពីរខាងលើនេះ គ្រួសារណាដែលមានស្ត្រីជាមេគ្រួសារ ហើយមានសមាជិកជាបុរសពេញវ័យ និងគ្រួសារណា ដែលមានសមាជិកធ្វើការចំណាកស្រុក គ្រួសារនោះមានភវនីយភាពនៃភាពក្រីក្រទាប។

ប៉ុន្តែកត្តាអថេរទាំងនេះ កំពុងជួបឧបសគ្គក្នុងអំឡុងពេលរាតត្បាតជំងឺកូវីដ-១៩។ ឧទាហរណ៍ការវិភាគទៅលើការធ្វើអង្កេត តាមទូរស័ព្ទអំឡុងកូវីដ-១៩ បង្ហាញឱ្យឃើញពីការបាត់បង់ប្រាក់ចំណូល មានភាពធ្ងន់ធ្ងរគិតជាទំហំ (ចំណែកភាគរយនៃគ្រួសារដែលរងផលប៉ះពាល់) និងជម្រៅ នៃការបាត់បង់ប្រាក់ចំណូលក្នុងចំណោមគ្រួសារនៃក្រុមដែលមានប្រាក់ចំណូលទាបជាងគេ (ក្រុមទាបជាងគេ ២០% និងក្រុមទាបបន្ទាប់ ២០%) ហើយសភាពធ្ងន់ធ្ងរនេះ ក៏កើតមានចំពោះគ្រួសារដែលមានបណ្ណសមធម៌ផងដែរ។ ម្យ៉ាងទៀត ការបាត់បង់ប្រាក់ចំណូល មិនត្រឹមតែមានសភាពលង់ជ្រៅប៉ុណ្ណោះទេ ម្យ៉ាងវិញទៀត ការបាត់បង់ប្រាក់ចំណូលនេះ នឹងកាន់តែមានសភាពលង់ជ្រៅបន្តទៅទៀត ដោយចាប់ផ្តើមពីកម្រិតទាបឡើងទៅ។ នេះបង្ហាញឱ្យឃើញថា មានដំណើរការនៃការធ្លាក់ខ្លួនក្នុងភាពក្រីក្រគួរឱ្យកត់សម្គាល់ (ទំហំ) ប៉ុន្តែ ក៏មានការធ្លាក់ខ្លួនក្នុងភាពក្រីក្ររាំរ៉ៃផងដែរ (ជម្រៅ) នៅប្រទេសកម្ពុជាដែលជាផលវិបាកនៃវិបត្តិជំងឺកូវីដ-១៩។

ការបាត់បង់ប្រាក់ចំណូល ពិតជាមានសភាពធ្ងន់ធ្ងរ។ សហគ្រាសដែលខុសពីវិស័យកសិកម្ម (NFEs) បានរងផលប៉ះពាល់ខ្លាំងជាងគេពីការបាត់បង់ប្រាក់ចំណូល នៅពេលដែលជំងឺរាតត្បាតចាប់ផ្តើមដំបូង។ លើសពីនេះ គិតត្រឹមខែមីនា ឆ្នាំ២០២១ ធៀបនឹងខែធ្នូ ឆ្នាំ២០២០ មួយភាគធំ ជាពិសេសគ្រួសារដែលមានបណ្ណសមធម៌ បានរាយការណ៍ពីការបាត់បង់ប្រាក់ចំណូលជាបន្តបន្ទាប់ ដែល

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

☞ អគារលេខ 56 ផ្លូវ 315, ទួលគោក
✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☎ +85523881701/881916/883603
អ៊ីម៉ែល: cdri@cdri.org.kh / www.cdri.org.kh

ជាប្រាក់ចំណូលធំរបស់ពួកគេ ដែលមានប្រភពពីសហគ្រាសដែលខុសពីវិស័យកសិកម្ម។ ការទទួលប្រាក់ផ្ញើមកផ្ទះ ត្រូវបានធ្លាក់ចុះយ៉ាងគំហុកផងដែរ ក្នុងអំឡុងពេលជំងឺរាតត្បាត។ លទ្ធផលទាំងនេះ ពិតជាគួរឱ្យព្រួយបារម្ភដោយសារថា ទាំងសហគ្រាសខុសពីវិស័យកសិកម្ម ទាំងការផ្ញើប្រាក់មកផ្ទះ គឺសុទ្ធតែមានទំនាក់ទំនងគ្នាយ៉ាងសំខាន់ ក្នុងការកាត់បន្ថយភាវនីយភាពនៃភាពក្រីក្រមុនពេលជំងឺកូវីដ-១៩ កើតឡើង ដែលបង្ហាញថា មាគ៌ាសំខាន់ៗដើម្បីចេញពីភាពក្រីក្រកំពុងជួបឧបសគ្គ។

ការអប់រំ គឺជាផ្នែកមួយទៀត ទាក់ទងនឹងសុខុមាលភាពនៅក្នុងប្រទេសកម្ពុជា ដែលផ្តល់ការការពារប្រឆាំងនឹងភាពក្រីក្រ មុនជំងឺរាតត្បាតមកដល់ ជាពិសេសនៅកម្រិតមធ្យមសិក្សាឡើងទៅ។ ប៉ុន្តែក្នុងអំឡុងពេលជំងឺកូវីដ-១៩ ការអប់រំការត្រូវបានរំខានគ្រប់ទីកន្លែង និងមានការបិទសាលារៀនម្តងហើយម្តងទៀត។ សូម្បីនៅកន្លែងដែលសកម្មភាពសិក្សាអប់រំ បានដំណើរការឡើងវិញ ក៏ការចូលរួមក្នុងចំណោមគ្រួសារក្រីក្រ នៅមានកម្រិតទាបនៅឡើយ។

ជាលទ្ធផលនៃការប៉ះទង្គិចផ្នែកទាំងនេះ គ្រួសារត្រូវបង្ខំចិត្តពឹងផ្អែកលើ យុទ្ធសាស្ត្រដោះស្រាយបញ្ហាមួយចំនួន ជាពិសេសការទិញរបស់ប្រើប្រាស់និងអាហារហូបចុក និងសម្រាប់គ្រួសារក្រីក្រនៅក្នុងការស្ទង់មតិលើកក្រោយៗទៀត ត្រូវពឹងផ្អែកលើលទ្ធភាពទទួលបាននូវកិច្ចគាំពារសង្គម។ ម្យ៉ាងទៀត ការពឹងផ្អែកលើការគាំទ្រពីមិត្តភ័ក្តិ ត្រូវបានកាត់បន្ថយដែលប្រហែលបណ្តាលមកពីការធ្លាក់ចុះនៃទំនាក់ទំនង និងបណ្តាញសហគមន៍។ ថ្វីដ្បិតការផ្តល់ជាសាច់ប្រាក់ បានទៅដល់គ្រួសារក្រីក្រដែលមានបណ្ណសមធម៌ជាច្រើន តែបរិមាណការផ្តល់ជាសាច់ប្រាក់នោះ អាចនឹងមិនគ្រប់គ្រាន់ទេ ដែលនាំឱ្យមានការកាត់បន្ថយការបរិភោគអាហារ ក្នុងចំណោមគ្រួសារក្រីក្រ និងនាំឱ្យមានអសន្តិសុខស្បៀងអាហារជាបន្តទៀត។ លើសពីនេះ ភាពមិនដូចគ្នានៅតាមតំបន់នានាក្នុងការទទួលបានកិច្ចគាំពារសង្គមនៅតែមាន ដូចនៅតំបន់បឹងទន្លេសាបជាដើម ដែលមានលក្ខខណ្ឌមិនអំណោយផល ដោយសារជាតំបន់ក្រីក្របំផុត នៅក្នុងប្រទេសរួចទៅហើយ មុនមានជំងឺរាតត្បាត។ នៅក្នុងបរិបទនេះ ការរំពឹងទុករបស់គ្រួសារនៅមានភាពស្រពេចស្រពិល សម្រាប់ប៉ុន្មានខែខាងមុខទៀតនេះ។

លទ្ធផលនៃសិក្សានេះ ចង្អុលប្រាប់ពីផ្នែកដែលត្រូវផ្តោតគោលនយោបាយ និងការបង្កើតកម្មវិធីនានា រួមទាំងការជួយបង្រួមគម្លាតនៃ ការអភិវឌ្ឍតាមតំបន់រស់នៅ រួមជាមួយនឹងការអភិវឌ្ឍតាមតំបន់ឱ្យប្រសើរឡើង ដោយផ្តោតលើតំបន់បឹងទន្លេសាប។ ជម្រើសដែលអាចជំនួសក្នុងការខ្ចីបុល ដែលជាយុទ្ធសាស្ត្រដោះស្រាយបញ្ហានោះ ក៏មានសារៈសំខាន់ ដែលគួរយកមកពិចារណាដែរ រួមនឹងការកែលម្អការប្រើប្រាស់ប្រកបដោយបរិយាបន្ននូវ សេវាហិរញ្ញវត្ថុដែលមានគុណភាព ដើម្បីជួយកាត់បន្ថយផលប៉ះពាល់ និងផលវិបាកនៃបំណុល។ ទន្ទឹមនេះ វាគឺជាតម្រូវការចាំបាច់មួយ ក្នុងការយកចិត្តទុកដាក់លើកុមារដែលខកខានក្នុងការទៅសាលារៀន និងមិនបានរៀនសូត្រ ជាពិសេសកុមារដែលមកពីគ្រួសារក្រីក្រ។

ដើម្បីទាញយករបាយការណ៍ពេញលេញ
សូមស្កេន QR code នេះ